**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍
# ប្រជុំរួមប្រចាំខែ វិច្ឆិកា ឆ្នាំ ២០១៣

នៅឆ្នាំពីរពាន់ដប់បី ខែធ្នូ ថ្ងៃទីដប់មួយ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំមន្ត្រីរាជការ បុគ្គលិក ទាំងអស់ប្រចាំខែ វិច្ឆិកា ឆ្នាំ២០១៣ ដែលដឹកនាំការប្រជុំដោយ **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះមាន៖ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន អនុប្រធាន នាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ និង មន្ត្រីរាជការ បុគ្គលិកទាំងអស់ មានចំនួន ៤៣ នាក់ ។

**អវត្តមាន**

| | | | |
|---|---|---|---|
| ១-ឯកឧត្តមវេជ្ជ. | ហោ ប៊ុនឡេង | អគ្គលេខាធិការរង | (ច្បាប់) |
| ២-លោកវេជ្ជ | រស់ សីលវ៉ាត់ | អគ្គលេខាធិការរង | (ឥតច្បាប់) |
| ៣-លោកស្រីវេជ្ជ. | សៀង សុរិយា | អគ្គលេខាធិការរង | (ឈឺ) |
| ៤-លោកស្រីវេជ្ជ. | ងិន លីណា | ប្រធាននាយកដ្ឋានPMER | (បេសកកម្ម) |
| ៥-លោកវេជ្ជ. | ជ វ៉ានី | អនុប្រធាននាយកដ្ឋានAF | (ឥតច្បាប់) |
| ៦-លោក | ហាង វិបុល | អនុប្រធាននាយកដ្ឋានAF | (ឥតច្បាប់) |
| ៧- លោកវេជ្ជ. | ផៃ ប៊ុនធូ | អនុប្រធាននាយកដ្ឋាន CRM | (ឥតច្បាប់) |
| ៨-លោកវេជ្ជ | គុជ សង្ហារ៉េត | មន្ត្រី | (ឈឺ) |
| ៩-លោកវេជ្ជ | ទុយ អមរិទ្ធ | មន្ត្រី | (ឥតច្បាប់) |
| ១០-លោកវេជ្ជ | អ៊ឹក ម៉ារឌី | អនុប្រធាននាយកដ្ឋាន PCS | (ឥតច្បាប់) |
| ១១-លោក | ចេង ថា | មន្ត្រី | (ឥតច្បាប់) |
| ១២-លោក | នាង សៅវុធី | ប្រធានការិយាល័យបុគ្គលិក | (ឈឺ) |

គោលបំណងនៃកិច្ចប្រជុំនេះមាន៖

1. ការងាររដ្ឋបាល និង POC
2. ការមានមតិលើកឡើងរបស់សមាជិកអង្គប្រជុំ
3. វិធានការ និង ទិសដៅសំរាប់អនុវត្តការងារបន្ត
4. សេចក្តីផ្សេងៗ

ជាកិច្ចចាប់ផ្តើម ឯកឧត្តមអគ្គលេខាធិការ ក៏បានមានមតិស្វាគមន៍ និង កោតសរសើរដល់មន្ត្រីដែលបានខិតខំបំពេញការងារ និង ជំរុញលើកទឹកចិត្តដល់មន្ត្រី បុគ្គលិកទាំងអស់ប្រឹងប្រែងធ្វើការងារបន្តទៅទៀត ។

**ការងាររដ្ឋបាល**

**លោក ឈឹម ឃិនដារ៉េត** ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ក៏បានលើកឡើងទាក់ទងទៅនឹងការងាររដ្ឋបាល មានដូចខាងក្រោម៖

- ចំពោះមន្ត្រីទាំងអស់ ដែលទទួលបានថវិកា POC ត្រូវបំពេញ
    1. កិច្ចសន្យាការងារពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៣
    2. របាយការណ៍ប្រចាំត្រីមាស និង ប្រចាំឆ្នាំ
    3. ទួនាទី និង ភារកិច្ច(TOR)
    4. បើកគណនីជាប្រាក់ដុល្លា

ចំពោះឯកសារទាំងអស់នេះ បំពេញហើយ ប្រគល់ទៅឲ្យ កញ្ញា គីម សុចិត្រា មិនឲ្យហួសពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៣ ឡើយ ។ បើមន្ត្រីណាមិនបានប្រគល់ឲ្យទៅតាមកាលបរិច្ឆេទនេះទេ នោះនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុមិនទទួលខុសត្រូវឡើយ ។ បើសិនជាមានការប្រែប្រួលផ្សេងទៀត នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នឹងផ្តល់ដំណឹងជាក្រោយ ។

- ដោយសារតែរាជរដ្ឋាភិបាល មានគោលការណ៍ឲ្យមន្ត្រីរាជការស៊ីវិលទាំងអស់ ដែលទទួលបានប្រាក់បៀវត្ស ត្រូវបើកគណនីនៅធនាគារ ACLEDA ព្រោះប្រាក់បៀវត្សរបស់មន្ត្រីរាជការ ចាប់ពីខែមករា ឆ្នាំ២០១៤ ទៅ គឺបើកនៅធនាគារវិញ ។
- នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៣ មន្ត្រីទាំងអស់ ត្រូវមកជួបជុំគ្នា ដើម្បីបើកគណនី ព្រោះភ្នាក់ងារ ACLEDA គេមកកន្លែងយើង ។

ឯកឧត្តមអគ្គលេខាធិការ បានលើកឡើងទាក់ទងទៅនឹងមន្ត្រី ដែលបានទទួលថវិកា POC

- តាមការប៉ាន់ស្មានរបស់នាយកដ្ឋាន បានតែ ៤០% ទេចំពោះមន្ត្រីដែលបានអនុវត្តការងារ ។
- តាមការណែនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ស្នើឲ្យអគ្គលេខាធិការដ្ឋាន ធ្វើសេចក្តីណែនាំមួយ ជូនទៅគ្រប់នាយកដ្ឋាន ដើម្បីស្នើសុំថវិកា POC ជូនមន្ត្រីរបស់ខ្លួន ។
- ប្រធាននាយកដ្ឋាននីមួយៗ ត្រូវទទួលខុសត្រូវ ក្នុងការអនុវត្តសកម្មភាពការងាររបស់មន្ត្រីក្រោមឱវាទ ។

ការពិភាក្សា

ឯកឧត្តមវេជ្ជ. ស៊ឹម គឹមសាន ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន បានលើកឡើងទាក់ទងទៅនឹងមន្ត្រីទទួលថវិកា POC ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានប្រគល់ជូនប្រធាននាយកដ្ឋាន ទទួលខុសត្រូវចំពោះមន្ត្រី ដែលទទួលថវិកា POC ហើយឯកឧត្តម បន្តទៀតថា ជាការមួយលំបាកបំផុតចំពោះមន្ត្រី ដែលមិនសូវមកធ្វើការងារ ។

ឯកឧត្តមអគ្គលេខាធិការ ផ្តល់ជាអនុសាសន៍ថា៖

- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ រាល់កិច្ចប្រជុំប្រចាំខែ ត្រូវយកច្បាប់លក្ខន្តិកៈមន្ត្រីរាជការស៊ីវិលមកជាមួយ ដើម្បីផ្សព្វផ្សាយដល់មន្ត្រី ។

**វិធានការសំរាប់អនុវត្តបន្ត**

1. នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវស្រង់បញ្ជីវត្តមានមន្ត្រី បុគ្គលិក ដែលមិនបានចូលប្រជុំរួមប្រចាំខែ ។
2. ចំពោះមន្ត្រីអវត្តមាននៅក្នុងកិច្ចប្រជុំរួមប្រចាំខែ ប្រធាននាយកដ្ឋាននីមួយៗ ត្រូវទទួលខុសត្រូវ ។
3. នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវរៀបចំជាប្រធានបទ នៅក្នុងកិច្ចប្រជុំប្រចាំខែ ។
4. ប្រធាន នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវពិនិត្យឲ្យបានត្រឹមត្រូវ និងទទួលខុសត្រូវ ចំពោះបុគ្គលិករណ្តែត កិច្ចសន្យា ។
5. មន្ត្រីទាំងអស់ ត្រូវទៅសួរសុខទុក្ខលោក គុជ សង្វាវេត ជាមន្ត្រីនាយកដ្ឋាន CRM នៅគេហដ្ឋានរបស់លោកផ្ទាល់ ។

ចុងបញ្ចប់អង្គប្រជុំនៅវេលាម៉ោង ១១:០០នាទី នាថ្ងៃ ខែ ឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយក្រៃលែង។

| | |
|---|---|
| បានឃើញ និង ឯកភាព<br>ប្រធានអង្គប្រជុំ | លេខាកត់ត្រា |
| ទដ្ឋ. តែង គន្ធី | ហ៊ិន សុ |

ក្នុងសីហ<br>18-12-13